00643397

E39

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១១

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 10 / 02 / 2011
ម៉ោង (Time/Heure): 9:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើរបស់មេធាវីការពារក្តីសុំអង្គជំនុំជម្រះសាលាដំបូងសម្រេចលើបញ្ហានានា ដែលមានលក្ខណៈសំខាន់ដល់ជនជាប់ចោទនៅកិច្ចប្រជុំរៀបចំសវនាការ

---

<u>ដាក់ដោយ</u>៖

**សហមេធាវីរបស់ អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLI, QC

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

PICH Ang

Elisabeth SIMONNEAU FORT

<u>ផ្ញើជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

## I សេចក្តីផ្តើម និង សំណូមពរ

១. មេធាវីការពារក្តី អៀង សារី នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ បានដាក់ញត្តិរបស់ "អៀង សារី សុំដំណើការសវនាការរយៈពេលកន្លះថ្ងៃ" ("សំណើ")[1] ។ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១១ សហព្រះរាជអាជ្ញាដាក់សេចក្តីកត់សម្គាល់របស់ពួកគេ លើញត្តិរបស់ អៀង សារី សុំដំណើរការសវនាការរយៈពេលកន្លះថ្ងៃ ("សេចក្តីកត់សម្គាល់")[2] ។

២. មេធាវីការពារក្តី អៀង សារី នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ បានដាក់ញត្តិរបស់ អៀង សារី ស្នើសុំការណែនាំអំពីការចូលរួមរបស់ ដើមបណ្តឹងរដ្ឋប្បវេណី[3] ។

៣. មេធាវីការពារក្តី អៀង សារី នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ បានដាក់ញត្តិរបស់ អៀង សារី សុំអង្គជំនុំជម្រះសលាដំបូងដំណើរការជំនុំជម្រះករណី ០០២ ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលត្រូវបានស្នើសុំ និងសំណើសុំបង្អង់ជាបន្ទាន់ដីកាបង្គាប់ឲ្យដាក់សម្ភារៈភស្តុតាងសម្រាប់ត្រៀមរៀបចំសវនាការ[4]។ នៅថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០១១ សហព្រះរាជអាជ្ញាដាក់ចម្លើយតបរបស់ពួកគេទៅនឹងញត្តិរបស់ អៀង សារី សុំអង្គជំនុំជម្រះសាលាដំបូងដំណើរការជំនុំជម្រះករណី ០០២ ដោយអនុវត្តតាមវិសោធនកម្មនីតិវិធី និងសំណើសុំផ្អាកជាបន្ទាន់ដីកាបង្គាប់ឲ្យដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការ[5] ។

---

[1] ញត្តិរបស់ អៀង សារី សុំដំណើរការសវនាការរយៈពេលកន្លះថ្ងៃ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ ឯកសារ E20 ។

[2] ការសង្កេតរបស់សហព្រះរាជអាជ្ញា លើញត្តិរបស់ អៀង សារី សុំដំណើរការសវនាការរយៈពេលកន្លះថ្ងៃ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E20/1 ។

[3] ញត្តិរបស់ អៀង សារី ស្នើសុំការណែនាំអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ឯកសារ E23 ។

[4] ញត្តិរបស់ អៀង សារី សុំអង្គជំនុំជម្រះសាលាដំបូងដំណើរការជំនុំជម្រះករណី ០០២ ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលត្រូវបានស្នើសុំ និងសំណើសុំផ្អាកជាបន្ទាន់ដីកាបង្គាប់ឲ្យដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ឯកសារ E9/3 ។

[5] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិរបស់ អៀង សារី សុំអង្គជំនុំជម្រះសាលាដំបូងដំណើរការជំនុំជម្រះករណី ០០២ ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលបានស្នើសុំ និងសំណើសុំផ្អាកជាបន្ទាន់ដីកាបង្គាប់ឲ្យដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារ E9/3/1 ។

៤. នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ (**ជនជាប់ចោទ**) ត្រូវបានជូនដំណឹងថាកិច្ចប្រជុំរៀបចំសវនាការ នឹងធ្វើឡើងនៅថ្ងៃទី៥-៦ ខែមេសា ឆ្នាំ២០១១ ហើយថារបៀបវារៈរបស់កិច្ចប្រជុំនេះ នឹងជូនដំណឹងនាពេលក្រោយ[6] ។

៥. នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្តីត្រូវបានជូនដំណឹងពី "ញត្តិ" របស់ អៀង សារី ប្រឆាំងនឹងការប្រើប្រាស់នៅសវនាការនូវភស្តុតាងដែលជិតដាមដោយការធ្វើទារុណកម្ម[7] ។

៦. មេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង សម្រេចនៅកិច្ចប្រជុំរៀបចំសវនាការលើបញ្ហានានា ដូចជាការដំណើរការជំនុំជម្រះរយៈពេលកន្លះថ្ងៃ ការណែនាំសម្រាប់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ការកែប្រែដំណើរការជំនុំជម្រះករណី ០០២ ការប្រើប្រាស់ភស្តុតាងដែលជិតដាមដោយការធ្វើទារុណកម្ម និងបញ្ហាផ្សេងៗទៀតដែលលើកឡើងនាពេលខាងមុខដោយភាគីដទៃទៀត ដែលសំខាន់ដល់ជនជាប់ចោទ ។

## II. **បទប្បញ្ញត្តិច្បាប់**

៧. វិធាន ៧៩(៧) ចែងថា៖

> ដើម្បីសម្របសម្រួលដល់ការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស អង្គជំនុំជម្រះសាលាដំបូង អាចពិគ្រោះយោបល់ជាមួយភាគីទាំងឡាយ ដោយធ្វើការកោះប្រជុំរៀបចំសវនាការ ប្រសិនបើយល់ឃើញថាចាំបាច់ ។ កិច្ចប្រជុំនេះត្រូវធ្វើឡើងជាសម្ងាត់ លើកលែងតែអង្គជំនុំជម្រះសាលាដំបូង សម្រេចផ្សេងពីនេះ ។ គោលបំណងនៃកិច្ចប្រជុំនេះ នឹងអនុញ្ញាតិឱ្យមានការផ្លាស់ប្តូរយោបល់គ្នារវាងភាគីទាំងឡាយ ដើម្បីសម្របសម្រួលការកំណត់កាលបរិច្ឆេទនៃការធ្វើសវនាការបឋម សវនាការនៃអង្គសេចក្តី និងពិនិត្យឡើងវិញនៃរឿងក្តី ដោយអនុញ្ញាតឱ្យជនជាប់ចោទលើកឡើងនូវបញ្ហាទាំងឡាយទាក់ទងនឹងរឿងក្តីនោះ រួមទាំងស្ថានភាពរូបកាយ និងស្មារតី ។

---

[6] អង្គជំនុំជម្រះសាលាដំបូង អនុស្សារណៈក្នុងការិយាល័យ "ការជូនដំណឹងពីកាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ (ថ្ងៃអង្គារ៍ ទី៥ ខែមេសា និងថ្ងៃ ពុធ ទី៦ ខែមេសា ឆ្នាំ២០១១) ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E9/5 ។

[7] ញត្តិរបស់ អៀង សារី ប្រឆាំងនឹងការប្រើប្រាស់នៅសវនាការនូវភស្តុតាងដែលជិតដាមដោយការធ្វើទារុណកម្ម ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារលេខ E33 ។

## III. អំណះអំណាង

៨. មេធាវីការពារក្ដីស្នើសូមឲ្យពិចារណាថា បញ្ហានៃការដំណើរការជំនុំជម្រះរយៈពេលកន្លះថ្ងៃ ការណែនាំសម្រាប់ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ការកែប្រែនីតិវិធីសម្រាប់ដំណើរការជំនុំជម្រះក្ដី និងការប្រើប្រាស់នៅសវនាការនូវភស្តុតាងដែលផិតដាមដោយការធ្វើទារុណកម្ម មិនត្រឹមតែមានសារៈសំខាន់ដល់មេធាវីការពារក្ដី អៀង សារី ប៉ុណ្ណោះទេ តែវាសំខាន់ដល់មេធាវីការពារក្ដីជនជាប់ចោទទាំងអស់ផងដែរ ។ បញ្ហាទាំងអស់នេះពាក់ព័ន្ធដោយផ្ទាល់ជាមួយនីតិវិធី និងការគ្រប់គ្រងការជំនុំជម្រះករណី ០០២ ដែលនឹងចាប់ផ្ដើមនៅចុងឆ្នាំនេះ ។ ដោយសារភាពសំខាន់របស់បញ្ហាទាំងនេះ មេធាវីការពារក្ដីយល់ឃើញថាភាគីទាំងអស់ដែលពាក់ព័ន្ធក្នុងកិច្ចដំណើរការនីតិវិធី រួមទាំងមេធាវីការពារជនជាប់ចោទ ត្រូវបានផ្ដល់ឱកាសឲ្យបញ្ចេញមតិយោបល់លើបញ្ហាទាំងនេះ។

៩. សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលនឹងមកដល់នេះ លើញត្តិរបស់ អៀង សារី សុំដំណើរការជំនុំជម្រះរយៈពេលកន្លះថ្ងៃ, ញត្តិរបស់ អៀង សារី ស្នើសុំការណែនាំសម្រាប់ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី, ញត្តិរបស់ អៀង សារី សុំអង្គជំនុំជម្រះសាលាដំបូងដំណើរការជំនុំជម្រះករណី ០០២ ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលបានស្នើសុំ និងញត្តិរបស់ អៀង សារី ប្រឆាំងនឹងការប្រើសប្រាស់នៅសវនាការនូវភស្តុតាងដែលផិតដាមដោយការធ្វើទារុណកម្ម នឹងប៉ះពាល់ដល់ការជំនុំជម្រះជនជាប់ចោទទាំងអស់ ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចលើបញ្ហានានាដែលប៉ះពាល់ដល់ជនជាប់ចោទទាំងអស់ មេធាវីការពារក្ដីសូមស្នើថាមេធាវីការពារក្ដីត្រូវតែបានផ្ដល់ឱកាសធ្វើសេចក្ដីសន្និដ្ឋានលើបញ្ហាទាំងនេះ បើទោះបីជាគេរំពឹងទុកថានឹងមិនសម្រេចលើបញ្ហាទាំងនេះ ដោយពុំមានការស៊ើបសួរបន្ថែមនោះ ។

១០. នៅក្នុងការសង្កេតរបស់ខ្លួនលើញត្តិរបស់ អៀង សារី សុំដំណើរការជំនុំជម្រះរយៈពេលកន្លះថ្ងៃ សហព្រះរាជអាជ្ញាដោះស្រាយបញ្ហាសំខាន់នៃការចូលរួមពីចំងាយរបស់ជនជាប់ចោទ ដោយប្រើឧបករណ៍សោតទស្សន៍ និងទូរទស្សន៍ ជំនួសឲ្យសិទ្ធិរបស់ជនជាប់ចោទត្រូវមានវត្តមាននៅសវនាការ[8] ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចលើញត្តិរបស់ អៀង សារី ដោយផ្អែក

---

[8] ការអង្កេតរបស់សហព្រះរាជអាជ្ញាលើញត្តិរបស់ អៀង សារី សុំដំណើរការជំនុំជម្រះរយៈពេលកន្លះថ្ងៃ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ E20/1 នៅកថាខណ្ឌទី ៦-៧ ។

លើអំណះអំណាងរបស់ អៀង សារី និងអំណះអំណាងរបស់សហព្រះរាជអាជ្ញាតែប៉ុណ្ណឹង ដោយពុំបានផ្តល់ឱកាសឱ្យមេធាវីការពារក្តីធ្វើសេចក្តីសន្និដ្ឋានលើបញ្ហាជាក់លាក់ នោះការសម្រេចរបស់អង្គជំនុំជម្រះ ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជនជាប់ចោទ ។

១១. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាលនាពេលថ្មីៗនេះ ដើម្បីដំណើការកិច្ចប្រជុំរៀបចំសវនាការ ជាមួយនឹងគោលបំណងសម្របសម្រួលដំណើរការនីតិវិធីដោយយុត្តិធម៌ និងឆាប់រហ័សដូចមានចែងនៅក្នុងវិធាន ៧៩(៧) ។

១២. ព្រោះតែជាបញ្ហាយុត្តិធម៌ មេធាវីការពារក្តីយល់ឃើញថាបញ្ហាទាំងបួនដែលលើកឡើងដោយមេធាវីការពារក្តី អៀង សារី ត្រូវតែបានពិភាក្សាក្នុងកិច្ចប្រជុំរៀបចំសវនាការ ហើយភាគីទាំងអស់ដែលពាក់ព័ន្ធក្នុងដំណើរការនីតិវិធី ត្រូវតែបានផ្តល់ឱកាសបញ្ចេញមតិយោបល់លើបញ្ហាទាំងនេះ ។ បញ្ហាទាំងនេះមានបញ្ហានីតិវិធីដែលជនជាប់ចោទនីមួយៗត្រូវតែមានសិទ្ធិដឹង។ មេធាវីការពារក្តីស្នើឱ្យពិចារណាថាកិច្ចប្រជុំរៀបចំសវនាការ ជាវេទិការដ៏សក្តិសមដើម្បីលើកបញ្ហាទាំងនេះ ។ ការរារាំងមេធាវីការពារក្តីមិនឱ្យបញ្ចេញទស្សនៈលើបញ្ហាទាំងនេះ នឹងធ្វើឱ្យនីតិវិធីមិនមានយុត្តិធម៌ ។

១៣. ដោយសារតែជាបញ្ហាប្រសិទ្ធិភាព មេធាវីការពារក្តីស្នើឱ្យពិចារណាថាដំណើការនីតិវិធីនឹងមិនប្រព្រឹត្តទៅឆាប់រហ័សបានទេ បើសិនអង្គជំនុំជម្រះសាលាដំបូងសម្រេចលើបញ្ហាទាំងនេះ ដោយមិនបានស្តាប់មតិយោបល់របស់ជនជាប់ចោទដទៃទៀត ។ ជនជាប់ចោទ និងជនជាប់ចោទដទៃទៀត នឹងស្វែងរកការលើកឡើងនូវបញ្ហាទាំងនេះ នៅមុនការចាប់ផ្តើមការជំនុំជម្រះករណី ០០២ ដោយសារតែជនជាប់ចោទទាំងបួននាក់នេះ នឹងត្រូវជំនុំជម្រះព្រមគ្នា ។ ជាលទ្ធផល មេធាវីការពារក្តីយល់ឃើញថា កិច្ចប្រជុំរៀបចំសវនាការដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥-៦ ខែមេសា ឆ្នាំ ២០១១ គឺជាពេលវេលាដ៏សក្តិសមបំផុតសម្រាប់ឱ្យភាគីទាំងអស់លើកឡើងនូវបញ្ហានានា ។

១៤. មេធាវីការពារក្តី អៀង សារី បានបញ្ជាក់នៅក្នុងញត្តិស្នើសុំរបស់ខ្លួនថា បញ្ហាទាំងអស់នេះត្រូវតែបានលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំរៀបចំសវនាការ “ដើម្បីឱ្យភាគីទាំងអស់បញ្ចេញមតិយោបល់របស់ពួកគេនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង”[9] ។

---

[9] ញត្តិរបស់ អៀង សារី សុំការណែនាំសម្រាប់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ឯកសារ E23, នៅទំព័រទី១ ។ សូមមើលផងដែរ ញត្តិរបស់ អៀង សារី សុំដំណើរការសវនាការរយៈពេលកន្លះថ្ងៃ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១១ ឯកសារ E20 នៅទំព័រទី១ ។ ញត្តិរបស់ អៀង សារី សុំអង្គជំនុំជម្រះសាលាដំបូងដំណើរការជំនុំជម្រះករណី ០០២

១៥. អាស្រ័យហេតុនេះ មេធាវីការពារក្ដីស្នើសុំឱ្យពិចារណាថាដំណើរការនីតិវិធី នឹងមិនមានយុត្តិធម៌ និងឆាប់រហ័សទេ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចលើបញ្ហាពិសេសទាំងនេះ ដោយមិនអនុញ្ញាតឱ្យភាគីដទៃទៀតនៃដំណើរការនីតិវិធី បញ្ចេញទស្សនៈរបស់ពួកគេលើបញ្ហាទាំងនេះ ។ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីទាំងអស់ថា របៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការនឹងជម្រាបនៅពេលក្រោយ។ មេធាវីការពារក្ដីស្នើសុំឱ្យពិចារណាថាបញ្ហានានាដូចជាការដំណើរការជម្រះជម្រះក្ដីរយៈពេលកន្លះថ្ងៃ, ការណែនាំសម្រាប់ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី, ការកែប្រែនីតិវិធីដំណើរការជំនុំជម្រះករណី ០០២ និងការប្រើប្រាស់នៅសវនាការនូវភស្ដុតាងដែលផិតដាមដោយការធ្វើទារុណកម្ម ត្រូវតែបានដាក់បញ្ចូលនៅក្នុងរបៀបវារៈរបស់កិច្ចប្រជុំរៀបចំសវនាការ ។

១៦. ស្រដៀងគ្នានេះដែរ ប្រសិនបើមានបញ្ហាសំខាន់ដទៃទៀតដែលទាក់ទងនឹងនីតិវិធីជំនុំជម្រះក្ដីនៅក្នុងករណី ០០២ ត្រូវបានលើកឡើងដោយភាគីនៃដំណើរការនីតិវិធី មេធាវីការពារក្ដីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង បន្ថែមបញ្ហាទាំងនេះចូលក្នុងរបៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីឱ្យភាគីទាំងអស់នៃដំណើរការនីតិវិធីដឹងឮពីបញ្ហាដែលបានលើកឡើង ។

## IV. សំណូមពរ

១៧. មេធាវីការពារក្ដីស្នើសុំអង្គជំនុំជម្រះសាលាដំបូង:

- ដាក់បញ្ចូលប្រធានបទមានជាអាទិ៍ ការដំណើរការជម្រះជម្រះក្ដីរយៈពេលកន្លះថ្ងៃ, ការណែនាំសម្រាប់ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី, ការកែប្រែនីតិវិធីដំណើរការជំនុំជម្រះករណី ០០២ និងការប្រើប្រាស់នៅសវនាការនូវភស្ដុតាងដែលផិតដាមដោយការធ្វើទារុណកម្ម នៅក្នុងរបៀបវារៈរបស់កិច្ចប្រជុំរៀបចំសវនាការ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥ និងទី៦ ខែមេសា ឆ្នាំ ២០១១ និង

---

ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលត្រូវបានស្នើសុំ និងសំណើសុំផ្អាកជាបន្ទាន់ដីកាបង្គាប់ឱ្យដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ឯកសារ E9/3 នៅកថាខណ្ឌទី៣៣ ។

- មិនត្រូវសម្រេចលើបញ្ហាទាំងអស់នេះនៅមុនភាគីទាំងអស់នៃកិច្ចដំណើរការនីតិវិធី បានដឹងឮនូវបញ្ហាទាំងនេះទេ ។
- ប្រសិនមានបញ្ហាផ្សេងទៀតដែលសំខាន់ចំពោះជនជាប់ចោទ ត្រូវបានលើកឡើងដោយភាគីមួយនៃកិច្ចដំណើរការនីតិវិធី បញ្ចូលបញ្ហានេះក្នុងរបៀបវារៈរបស់កិច្ចប្រជុំរៀបចំសវនាការ និងមិនត្រូវសម្រេចលើបញ្ហានេះនៅមុនភាគីទាំងអស់នៃកិច្ចដំណើរការនីតិវិធី បានដឹងឮបញ្ហានោះឡើយ ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះរបស់មេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី១០ ខែ កុម្ភៈ ឆ្នាំ២០១១ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | [signature and stamp: AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA] |